# សិរីមន្តជាតក




*សិរិមន្តបញ្ហានេះ មានពាក្យថា* **បញ្ញាយុបេតំ សិរិយា វិហីនំ** *ដូច្នេះជាដើម នឹងមានដាក់ក្នុងមហាឧមង្គជាត (មហាសថជាតក) ។*

***ខាងក្រោមនេះជាសេចក្ដីដែលមានមកក្នុងព្រះបាលី ៖***

(ព្រះរាជាវិទេហៈត្រាស់សួរថា)

បញ្ញាយុបេតំ សិរិយា វិហីនំ, យសស្សិនំ វាបិ អបេតបញ្ញំ;
បុច្ឆាមិ តំ សេនក ឯតមត្ថំ, កមេត្ថ សេយ្យោ កុសលា វទន្តិ។

*នៃសេនកៈ យើងសួរនូវសេចក្ដីនុ៎ះ គឺបុគ្គលប្រកបដោយប្រាជ្ញាតែប្រាសចាកសិរីសម្បត្តិ ១ បុគ្គលមានយសតែប្រាសចាកប្រាជ្ញា ១ អ្នកប្រាជ្ញទាំងឡាយពោលថា បណ្ដាបុគ្គលទាំងពីរនោះ បុគ្គលណា ប្រសើរជាង ។*

(អាចារ្យសេនកៈទូលថា)

ធីរា ច ពាលា ច ហវេ ជនិន្ទ, សិប្បូបបន្នា ច អសិប្បិនោ ច;
សុជាតិមន្តោបិ អជាតិមស្ស, យសស្សិនោ បេសករា ភវន្តិ;
ឯតម្បិ ទិស្វាន អហំ វទាមិ, បញ្ញោ និហីនោ សិរីមាវ សេយ្យោ។

*បពិត្រព្រះអង្គជាធំជាងជន ពួកជនប្រាជ្ញ ពួកជនពាល ពួកជនអ្នកបរិបូណ៌ដោយសិល្បៈ និងពួកជនមិនមានសិល្បៈ សូម្បីជាអ្នកមានជាតិខ្ពស់ រមែងជាអ្នកធ្វើនូវការបម្រើជនអ្នកមានយស ដែលមិនមានជាតិ ខ្ញុំព្រះអង្គបានឃើញហេតុនេះ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។*

(ព្រះរាជាវិទេហៈត្រាស់ថា)

តុវម្បិ បុច្ឆាមិ អនោមបញ្ញ, មហោសធ កេវលធម្មទស្សិ;
ពាលំ យសស្សឹ បណ្ឌិតំ អប្បភោគំ, កមេត្ថ សេយ្យោ កុសលា វទន្តិ។

*ម្នាលមហោសធ អ្នកមានប្រាជ្ញាមិនថោកថយ ជាអ្នកឃើញនូវហេតុដោយសព្វគ្រប់ យើងសូមសួរអ្នក អំពីបុគ្គលពាលមានយស បណ្ឌិតគ្មានភោគៈ តើអ្នកប្រាជ្ញទាំងឡាយពោលថា បណ្ដាបុគ្គលទាំងពីរនោះ បុគ្គលណាប្រសើរជាង ។*

(ព្រះមហោសធបណ្ឌិតទូលថា)

ចាចានិ កម្មានិ ករោតិ ពាលោ, ឥធមេវ សេយ្យោ ឥតិ មញ្ញមានោ;
ឥធលោកទស្សី បរលោកមទស្សី, ឧភយត្ថ ពាលោ កលិមគ្គហេសិ;
ឯតម្បិ ទិស្វាន អហំ វទាមិ, បញ្ញោវ សេយ្យោ ន យសស្សិ ពាលោ។

*ពួកជនពាល តែងធ្វើនូវអំពើអាក្រក់ទាំងឡាយ ហើយសំគាល់ថា អំពើនេះឯង ជាអំពើប្រសើរ ជាអ្នកឃើញត្រឹមតែលោកនេះ មិនឃើញនូវលោកខាងមុខទេ បុគ្គលពាលតែងកាន់យកនូវទោសក្នុងលោកទាំងពីរ ខ្ញុំព្រះអង្គបានឃើញហេតុនេះ សូមទូលថា បុគ្គលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរទេ ។*

(អាចារ្យសេនកៈទូលថា)

ន សិប្បមេតំ វិទធាតិ ភោគំ, ន ពន្ធុវា ន សរីរវណ្ណោ យោ;
បស្សេឡមូគំ សុខមេធមានំ, សិរី ហិ នំ ភជតេ គោរវិន្ទំ;
ឯតម្បិ ទិស្វាន អហំ វទាមិ, បញ្ញា និហីនោ សិរីមាវ សេយ្យោ។

*សិល្បៈនេះ រមែងមិនដល់នូវភោគសម្បត្តិទេ បុគ្គលមានផៅពង្ស ក៏មិនដល់នូវបុគ្គលមានភោគសម្បត្តិដែរ ទាំងបុគ្គលអ្នកមានឱកាសនៃសរីរៈ (មានរូបឆោមល្អ) ក៏មិនដល់នូវបុគ្គលមានភាគសម្បត្តិដែរ សូមទ្រង់ទតចុះ អ្នកផងតែងគប់រកនូវគោរវិន្ទសេដ្ឋី ជាមនុស្សហៀរទឹកមាត់ដល់នូវសេចក្ដីសុខ ជាអ្នកសាបសូន្យចាកសិរី ខ្ញុំព្រះអង្គបានឃើញហេតុនេះ ហើយទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ។*

(ព្រះមហោសធបណ្ឌិតទូលថា)

លទ្ធា សុខំ មជ្ជតិ អប្បបញ្ញោ, ទុក្ខេន ផុដ្ឋោបិ បមោហមេតិ;
អាគន្តុជា ទុក្ខសុខេន ផុដ្ឋោ, បវេធតិ វារិចរោវ ឃម្មេ;

ឯតម្បិ ឥស្វាន អហំ វទាមិ, បញ្ញាវ សេយ្យោ ន យសស្សិ ពាលោ។

*បុគ្គលអប្បប្រាជ្ញា បានសេចក្តីសុខហើយ រមែងស្រវឹង លុះត្រូវសេចក្តីទុក្ខប៉ះពាល់វិញ ក៏ដល់នូវសេចក្តីវង្វេង បុគ្គលអប្បប្រាជ្ញា ត្រូវសេចក្តីសុខនិងទុក្ខថ្មីមកប៉ះពាល់ហើយ ក៏រមែងញាប់ញ័រ ដូចជាវារិចរ (សត្វត្រេចទៅក្នុងទឹក) ដែលញាប់ញ័រក្នុងកាលក្តៅ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរ ។*

(អាចារ្យសេនកៈទូលថា)

ទុមំ យថា សាទុផលំ អរញ្ញេ, សមន្តតោ សមភិសរន្តិ បក្ខី;
ឯវម្បិ អឌ្ឍំ សធនំ សភោគំ, ពហុជ្ជនោ ភជតិ អត្ថហេតុ;
ឯតម្បិ ឥស្វាន អហំ វទាមិ, បញ្ញោ និហីនោ សិរីមាវ សេយ្យោ។

*ពួកសត្វបក្សី តែងហើរសំដៅទៅចោមរោមដើមឈើ ដែលមានផ្លែដ៏ឆ្ងាញ់ក្នុងព្រៃយ៉ាងណា ជនជាច្រើនតែងគប់រក នូវបុគ្គលស្តុកស្តម្ភ បរិបូណ៌ដោយទ្រព្យនិងភោគៈ ព្រោះហេតុតែប្រយោជន៍ ក៏យ៉ាងនោះដែរ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។*

(ព្រះមហោសធបណ្ឌិតទូលថា)

ន សាធុ ពលវា ពាលោ, សាហសា វិន្ទតេ ធនំ;
កន្ទន្តមេតំ ទុម្មេធំ, កឌ្ឍន្តិ និរយំ ភុសំ;
ឯតម្បិ ឥស្វាន អហំ វទាមិ, បញ្ញាវ សេយ្យោ ន យសស្សិ ពាលោ។

*បុគ្គលពាលមានកម្លាំង រមែងបាននូវទ្រព្យ (ព្រោះតែធ្វើ) នូវកម្មដ៏ក្លៀវក្លា មិនល្អទេ ពួកនិរយបាលតែងទាញកន្ត្រាក់នូវបុគ្គលពាលឥតប្រាជ្ញា ដែលកន្ទក់កន្ទេញនោះ យកទៅកាន់នរកដ៏ក្លៀវក្លា ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលអ្នកមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរ ។*

(អាចារ្យសេនកៈទូលថា)

យា កាចិ នជ្ជោ គង្គមភិស្សវន្តិ, សព្ពាវ តា នាមគោត្តំ ជហន្តិ;
គង្គា សមុទ្ទំ បដិបជ្ជមានា, ន ខាយតេ ឥទ្ធឹ បញ្ញោបិ លោកេ;
ឯតម្បិ ទិស្វាន អហំ វទាមិ, បញ្ញោ និហីនោ សិរីមាវ សេយ្យោ។

*ទឹកស្ទឹងទាំងឡាយណាមួយ រមែងហូរចាក់ទៅទន្លេគង្គា ទឹកស្ទឹងទាំងអស់នោះ រមែងលះបង់នូវនាមនិងគោត្រ ទឹកទន្លេកាលបើហូរដល់សមុទ្រ (រមែងបានឈ្មោះថាមហាសមុទ្រយ៉ាណា) បុគ្គលដែលមានប្រាជ្ញា ជាគ្រឿងសម្រេច ក៏មិនប្រាកដក្នុងលោកយ៉ាងនោះដែរ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។*

(ព្រះមហោសធបណ្ឌិតទូលថា)

យមេតមក្ខា ឧទធឹ មហន្តំ, សវន្តិ នជ្ជោ សព្ពកាលមសង្ខ្យំ;
សោ សាគរោ និច្ចមុឡាររវេគោ, វេលំ ន អច្ចេតិ មហាសមុទ្ទោ។

*លោកសេនកៈបានពោលនូវមហាសមុទ្រណា ថាជាសមុទ្រធំ ទឹកស្ទឹងទាំងឡាយតែងហូរទៅក្នុងសមុទ្រនោះរាប់មិនបាន អស់កាលទាំងពួង សមុទ្រនោះ មានសន្ទុះដ៏លើសលប់ជានិច្ចមែន តែថា ទឹកមហាសមុទ្រក៏មិនកន្លងនូវច្រាំងបានទេ ។*

ឯវម្បិ ពាលស្ស បជប្បិតានិ, បញ្ញំ ន អច្ចេតិ សិរី កទាចិ;
ឯតម្បិ ទិស្វាន អហំ វទាមិ, បញ្ញោវ សេយ្យោ ន យសស្សិ ពាលោ។

*ការប្រឹក្សារបស់មនុស្សពាល ក៏យ៉ាងនោះដែរ តាំងពីកាលណាមក បុគ្គលអ្នកមានសិរីរមែងមិនកន្លងនូវបុគ្គលមានប្រាជ្ញាឡើយ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលអ្នកមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរ ។*

(អាចារ្យសេនកៈទូលថា)

អសញ្ញតោ ចេបិ បរេសមត្ថំ, ភណាតិ សន្ធានគតោ យសស្សី;
តស្សេវ តំ រូហតិ ញាតិមជ្ឈេ, សិរី ហិ នំ ការយតេ ន បញ្ញា;
ឯតម្បិ ទិស្វាន អហំ វទាមិ, បញ្ញោ និហីនោ សិរីមាវ សេយ្យោ។

*បុគ្គលមានយសឋិតនៅក្នុងទីវិនិច្ឆ័យ បើទុកជាមិនព្រមព្រៀងទុក ក៏អាចប្រាប់នូវសេចក្តីចំពោះពួកជនដទៃបាន សំដីរបស់បុគ្គលមានយសនោះឯង រមែងលូតលាស់ក្នុងកណ្តាលនៃពួកញាតិ អ្នកផងមិនអាចញ៉ាំងបុគ្គលដែលមានប្រាជ្ញា តែសាបសូន្យចាកសិរី ឲ្យធ្វើការ (អ្វី) បានទេ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។*

(ព្រះមហោសធបណ្ឌិតទូលថា)

បរស្ស វា អត្តនោ វាបិ ហេតុ, ពាលោ មុសា ភាសតិ អប្បបញ្ញោ;
សោ និន្ទិតោ ហោតិ សភាយ មជ្ឈេ, បច្ឆាបិ សោ ទុគ្គតិគាមី ហោតិ;
ឯតម្បិ ទិស្វាន អហំ វទាមិ, បញ្ញោវ សេយ្យោ ន យសស្សិ ពាលោ។

បុគ្គលពាលអប្បប្រាជ្ញា រមែងនិយាយកុហក ព្រោះហេតុនៃអ្នកដទៃឬខ្លួនឯង បុគ្គលពាលនោះ ត្រូវគេតិះដៀលក្នុងកណ្ដាលទីប្រជុំ ក្នុងកាលខាងក្រោយ បុគ្គលពាលនោះ រមែងទៅកាន់ទុគ្គតិ ខ្ញុំព្រះអង្គបានឃើញហើយហេតុនេះ ទើបទូលថា បុគ្គលអ្នកមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរ ។

(អាចារ្យសេនកៈទូលថា)

អត្ថម្បិ ចេ ភាសតិ ភូរិបញ្ញោ, អនាឍ្យោ អប្បធនោ ទលិទ្ទោ;
ន តស្ស តំ រូហតិ ញាតិមជ្ឈេ, សិរី ច បញ្ញាណវតោ ន ហោតិ;
ឯតម្បិ ទិស្វាន អហំ វទាមិ, បញ្ញោ និហីនោ សិរីមាវ សេយ្យោ។

បុគ្គលមានប្រាជ្ញាក្រាសដូចផែនដី មិនមានទីនៅ មិនមានទ្រព្យធន ជាបុគ្គលក្រីក្រ បើទុកជាពោលនូវសេចក្ដី (ណាមួយ) ពាក្យសំដីរបស់បុគ្គលដែលមានប្រាជ្ញានោះ ក៏មិនលូតលាស់ក្នុងកណ្ដាលនៃពួកញាតិ ទាំងសិរីរបស់បុគ្គលមានប្រាជ្ញាក៏មិនមាន ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។

(ព្រះមហោសធបណ្ឌិតទូលថា)

បរស្ស វា អត្តនោ វាបិ ហេតុ, ន ភាសតិ អលិកំ ភូរិបញ្ញោ;
សោ បូជិតោ ហោតិ សភាយ មជ្ឈេ, បច្ឆាបិ សោ សុគ្គតិគាមី ហោតិ;
ឯតម្បិ ទិស្វាន អហំ វទាមិ, បញ្ញោវ សេយ្យោ ន យសស្សិ ពាលោ។

បុគ្គលអ្នកមានប្រាជ្ញាក្រាសដូចផែនដី រមែងមិននិយាយពាក្យឡេះឡោះ ព្រោះហេតុនៃបុគ្គលដទៃឬខ្លួនឯងទេ បុគ្គលអ្នកមានប្រាជ្ញានោះ មានគេបូជាក្នុងកណ្ដាលទីប្រជុំ លុះ

*កាលខាងក្រោយ អ្នកមានប្រាជ្ញានោះ រមែងទៅកាន់សុគតិ ខ្ញុំព្រះអង្គបានឃើញហើយហេតុនេះ ទើបទូលថា បុគ្គលអ្នកមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរ ។*

(អាចារ្យសេនកៈទូលថា)

ហត្ថី គវស្សា មណិកុណ្ឌលា ច, ថិយោ ច ឥទ្ធេសុ កុលេសុ ជាតា;
សព្ពាវ តា ឧបភោគា ភវន្តិ, ឥទ្ធស្ស បោសស្ស អនិទ្ធិមន្តោ;
ឯតម្បិ ទិស្វាន អហំ វទាមិ, បញ្ញោ និហីនោ សិរីមាវ សេយ្យោ។

*ដំរី គោ សេះ កែវមណី កុណ្ឌល និងនារី តែងកើតមានក្នុងត្រកូលអ្នកស្តុកស្តម្ភ ដំរី គោ សេះ ជាដើម ទាំងអស់នោះ ជារបស់មិនមានឫទ្ធិ ទើបជាគ្រឿងឧបភោគ (ប្រើប្រាស់) របស់បុរសជាឥស្សរៈ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។*

(ព្រះមហោសធបណ្ឌិតទូលថា)

អសំវិហិតកម្មន្តំ, ពាលំ ទុម្មេធមន្តិនំ;
សិរី ជហាតិ ទុម្មេធំ, ជិណ្ណំវ ឧរគោ តចំ;
ឯតម្បិ ទិស្វាន អហំ វទាមិ, បញ្ញោវ សេយ្យោ ន យសស្សិ ពាលោ។

*សិរីគឺឥស្សរិយយស រមែងលះបង់នូវបុគ្គលពាល ដែលមិនចេះចាត់ចែងនូវការងារ ជាអ្នកមានគំនិតអាក្រក់ ឥតប្រាជ្ញា ដូចពស់ដែលលះចោលនូវសំណកចាស់ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលអ្នកមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរទេ ។*

(អាចារ្យសេនកៈទូលថា)

បញ្ច បណ្ឌិតា មយំ ភទ្ទន្តេ, សព្ពេ បញ្ជលិកា ឧបដ្ឋិតា;
ត្វំ នោ អភិភុយ្យ ឥស្សរោសិ, សក្កោវ ភូតបតិ ទេវរាជា;
ឯតម្បិ ទិស្វាន អហំ វទាមិ, បញ្ញោ និហីនោ សិរីមាវ សេយ្យោ។

*បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គទាំង ៥ នាក់ សុទ្ធសឹងជាបណ្ឌិត ប្រណម្យដៃបម្រើព្រះអង្គទាំងអស់គ្នា ព្រះអង្គជាធំលើសលប់លើពួកខ្ញុំព្រះអង្គ ដូចជាទេវរាជៈឈ្មោះសក្កៈជាម្ចាស់នៃទេវតា ខ្ញុំព្រះអង្គបានឃើញហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ ។*

(ព្រះមហោសធបណ្ឌិតទូលតបកាត់ផ្តាច់វាទៈអាចារ្យសេនកៈថា)

ទាសោវ បញ្ញស្ស យសស្សិ ពាលោ, អត្ថេសុ ជាតេសុ តថាវិធេសុ;
យំ បណ្ឌិតោ និបុណំ សំវិធេតិ, សម្មោហមាបជ្ជតិ តត្ថ ពាលោ;
ឯតម្បិ ទិស្វាន អហំ វទាមិ, បញ្ញោវ សេយ្យោ ន យសស្សិ ពាលោ។

*បុគ្គលពាលដែលមានយស ទុកដូចជាទាសៈ របស់បុគ្គលអ្នកមានប្រាជ្ញា នាកាលហេតុទាំងឡាយប្រាកដដូច្នោះកើតហើយ អ្នកប្រាជ្ញាតាក់តែងនូវប្រស្នាដ៏ល្អិតណា បុគ្គលពាលរមែងដល់នូវការវង្វេងក្នុងប្រស្នាដ៏ល្អិតនោះ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលអ្នកមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរទេ ។*

អទ្ធា ហិ បញ្ញាវ សតំ បសត្ថា, កន្តា សិរី ភោគរតា មនុស្សា;
ញាណញ្ច ពុទ្ធានមតុល្យរូបំ, បញ្ញំ ន អច្ចេតិ សិរី កទាចិ។

*តាមពិត ពួកសប្បុរស តែងសរសើរប្រាជ្ញាតែម្យ៉ាង ពួកមនុស្សតែងត្រេកអរចំពោះភោគៈ សិរីគ្រាន់តែជាទីត្រេកអររបស់ (ពួកមនុស្សពាល) មួយទៀត ញាណនៃអ្នកប្រាជ្ញទាំងឡាយមិនមានអ្វីប្រៀបផ្ទឹមបានទេ តាំងពីកាលណាមក បុគ្គលអ្នកមានសិរី រមែងមិនកន្លងនូវបុគ្គលមានប្រាជ្ញាបានឡើយ ។*

(ព្រះចាតុរិតហេរាជត្រាស់ថា)

យំ តំ អបុច្ឆិម្ហ អកិត្តយី នោ, មហោសធ កេវលធម្មទស្សី;
គវំ សហស្សំ ឧសភញ្ច នាគំ, អាជញ្ញយុត្តេ ច រថេ ទស ឥមេ;
បញ្ហស្ស វេយ្យាករណេន តុដ្ឋោ, ទទាមិ តេ គាមវរានិ សោឡសៈ។

*ម្នាលមហោសធ ជាអ្នកឃើញធម៌សព្វគ្រប់ យើងបានសួរនូវប្រស្នាណា អ្នកបានថ្លែងដោះស្រាយនូវប្រស្នានោះដល់យើង យើងត្រេកអរដោយការដោះស្រាយនូវប្រស្នា (របស់យើង) យើងសូមឲ្យទ្រព្យទាំងនេះ គឺគោមួយពាន់ មានគោឧសភៈ (ជាដើម) ផង ដំរីផង រថដែលទឹមដោយសេះអាជានេយ្យ ១០ ផង ស្រុកសួយ ១៦ ផង ដល់អ្នក ។*

*(សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក វីសតិនិបាត បិដកលេខ ៦០ ទំព័រ ៨០ និងអដ្ឋកថា)*

*ថ្ងៃ ច័ន្ទ ១១ កើត ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ២៣ ខែ កក្កដា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ.*